**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃពីឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និង តាមព្រះរាជឱង្ការបង្គាប់

**ប្រមុខរដ្ឋស្តីទី**

ហត្ថលេខា

**ជា ស៊ីម**

* * *

## II - រាជរដ្ឋាភិបាល

## ១_អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ : ១៦ អនក្រ.បក**

**ស្តីពីការបង្កើតឧទ្យានជាតិ**

**សំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន**

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណរដ្ឋមន្ត្រី

Downloaded from http://www.khmerlaws.com

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីការចាត់តាំង និងការប្រព្រឹត្តិទៅ នៃប្រព័ន្ធសិរបសម្រួលផ្ទៃក្នុង
- បានឃើញព្រះរាជក្រឹត្យលេខ រកត.០៧៩៦.២៩ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីការតែងតាំងលោក អូនព័ន្ធមុន្នីរ័ត ជាឧត្តមមន្ត្រីសេដ្ឋកិច្ច អមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានឋានៈស្មើ អគ្គលេខាធិការ
- យោងតាមតម្រូវការចាំបាច់ នៃការងារ

**សម្រេច**

**មាត្រា ១** : បង្កើតអង្គភាពជាតិសម្រាប់តំបន់ពាណិជ្ជកម្មសេរី អាស៊ាន នៅក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ដែលជាភាសាអង់គ្លេសហៅថា «The National ASEAN Free Trade Area Unit »ហៅកាត់ថា «អង្គភាពជាតិ AFTA ឬ «National AFTA Unit »

**មាត្រា ២** :–អង្គភាពជាតិសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ានមានសមាសភាពដូចខាងក្រោម -

| | |
|---|---|
| ១–ឧត្តមមន្ត្រីសេដ្ឋកិច្ចអមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ប្រធាន |
| ២–ឧត្តមមន្ត្រីសេដ្ឋកិច្ចរង អមក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣–តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៤–តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥–តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៦–តំណាងក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល | សមាជិក |
| ៧–តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៨–តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩–តំណាងក្រសួងផែនការ | សមាជិក |
| ១០–នាយកទីចាត់ការគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

Downloaded from http://www.khmerlaws.com

១១-នាយក នៃនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១២-នាយក នៃនាយកដ្ឋានអាស៊ាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

**មាត្រា ៣ :** អង្គភាពជាតិសំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន ប្រើប្រាស់នាយកដ្ឋានអាស៊ានរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាសេនាធិការ និងជាលេខាធិការដ្ឋានរបស់ខ្លួន ។

**មាត្រា ៤ :** អង្គភាពជាតិសំរាប់តំបន់ពាណិជ្ជកម្មសេរី អាស៊ានមានភារកិច្ចដូចតទៅ ÷

ក/-ជួយផ្តល់មន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា ក្នុងការរៀបចំគោលនយោបាយ និងកំណត់យុទ្ធសាស្ត្រកម្ពុជា ក្នុងការចូលជាសមាជិកនៃ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងក្នុងការអនុវត្តន៍កិច្ចព្រមព្រៀង ស្តីពីការ អនុគ្រោះពន្ធគយរួមសំរាប់ AFTA(Agreement on Common Effective Preferential Tariff (CEPT) Scheme for the AFTA ) ។

ខ/-ទទួលបន្ទុកក្នុងការអនុវត្តន៍កិច្ចព្រមព្រៀង ស្តីពីការអនុគ្រោះពន្ធគយរួម ក្នុងនោះមាន ÷

- ការរៀបចំបញ្ជីទំនិញសំរាប់បញ្ចូលក្នុង CEPT Sheme ដែលក្នុងនោះរួមមាន ÷ បញ្ជីទំនិញសំរាប់បញ្ចូលក្នុង តារាងអនុគ្រោះពន្ធគយរួម ( Inclusion List ) បញ្ជីទំនិញដែលត្រូវដកចេញពីតារាងអនុគ្រោះពន្ធគយរួមជា បណ្តោះអាសន្ន ( Temporary Exclusion List ) បញ្ជីទំនិញដែលមានវេទយិតភាព និងបញ្ជីទំនិញដែលត្រូវ លើកលែងជាទូទៅ ( Sensitive and General Exception Lists ) ។

- ការរៀបចំកម្មវិធី និងកាលវិភាគ នៃការកាត់បន្ថយពន្ធគយសំរាប់ CEPT Scheme ។

- ការរៀបចំ «សៀវភៅផ្លាស់ប្តូរការអនុវត្តគ្រោះពន្ធគយសំរាប់ CEPT » ( CEPT Concessions Exchange Manual : CCEM )

- ការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍កិច្ចព្រមព្រៀង ស្តីពីការអនុគ្រោះពន្ធគយ ។

-កិច្ចការទំនាក់ទំនងសាធារណៈជាមួយផ្នែកឯកជនចំពោះការងារនានា ដែលមានការពាក់ព័ន្ធដល់ការអនុវត្តន៍កិច្ច ព្រមព្រៀង ស្តីពីការអនុគ្រោះពន្ធគយ ។

គ_តាមដាននិងវាយតម្លៃលើការអនុវត្តន៍កិច្ចព្រមព្រៀងស្តីពីការអនុវត្តន៍អនុគ្រោះពន្ធគយ ។

Downloaded from http://www.khmerlaws.com

ឃ- ទទួលបន្ទុកជា « បំពង់ទំនាក់ទំនង » ( Focal Point ) នៅក្នុងទំនាក់ទំនងការងារ AFTA ជាមួយ លេខាធិការដ្ឋានអាស៊ាន និងជាមួយប្រទេសសមាជិកអាស៊ានដទៃទៀត ។

ង- សិក្សាស្រាវជ្រាវ និងអនុវត្តកិច្ចសហប្រតិបត្តិការដទៃទៀតក្នុងក្របខ័ណ្ឌតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ។

**មាត្រា ៥ :** សមាជិកនៃអង្គភាពជាតិសំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន បំពេញការងារស្របតាមការអញ្ជើញរបស់ប្រធាន ។

**មាត្រា ៦ :** អង្គភាពជាតិសំរាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន មានសិទ្ធិអញ្ជើញមន្ត្រីជំនាញ នៃក្រសួង និងស្ថាប័នពាក់ព័ន្ធនានាមកចូលរួមប្រជុំ ដើម្បីពិភាក្សា និងដោះស្រាយការងារផ្សេងៗ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ។

**មាត្រា ៧ :** អង្គភាពជាតិសំរាប់ពាណិជ្ជកម្មសេរីអាស៊ានត្រូវរាយការណ៍ជាប្រចាំអំពីការងាររបស់ខ្លួន ដូចមានចែងក្នុងមាត្រា ៤ មកទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា៨ :** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្តលេខា និងត្រា ហត្ថលេខានិងត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

Downloaded from http://www.khmerlaws.com